ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លេខ ០២៥ /សសគម/២០១៨

ប្រធានគណៈមេធាវី

មេធាវី សួន វិសាល

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង ចន្ទ្រះ

២-មេធាវី អ៊ឹង កិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ឹម ប៉ូលី

៥-មេធាវី ទៀង សំបូរ

៦-មេធាវី ជា សុកខួន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លឹម សុវណ្ណា

១៤-មេធាវី ឈឹម តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មានឌួ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី គឹង

១៩-មេធាវី យឹម វិស្សុត

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កៃ វិសាល

២២-មេធាវី ហូ ឈីហួច

២៣-មេធាវី ចាំ ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ

# សេចក្តីសម្រេច

## ស្តីពី

## គោលការណ៍នៃការទទួល ការបែងចែក ការគ្រប់គ្រង និងការចំណាយ លើការការពាររឿងក្តីជូនជនក្រីក្រ

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញកំណត់ហេតុមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន វិសាល** ជាប្រធានគណៈមេធាវីអាណត្តិទី១១
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨។

## ស ម្រេ ច

ដាក់ឱ្យអនុវត្តគោលការណ៍ នៃការទទួល ការបែងចែក ការគ្រប់គ្រង និងការចំណាយលើការការពាររឿងក្តីជូនជនក្រីក្រ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១១ ខែមករា ឆ្នាំ ២០១៨ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ ៖

**ប្រការ ១. គោលបំណង**

គោលការណ៍នេះ មានគោលបំណងផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ជូនជនក្រីក្រ ឱ្យមានប្រសិទ្ធភាព និងមានតម្លាភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។



អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bakc.org.kh

## ប្រការ ២. ការទទួលរឿងក្ដី

### ២.១ ប្រភេទ និងលក្ខខណ្ឌនៃការទទួលរឿងក្ដី

ដោយផ្អែកលើមាត្រា ២៩ នៃច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាប័នតែមួយគត់ ដែលទទួលខុសត្រូវក្នុងការផ្ដល់សេវាកម្មការពារក្ដីជូនជនជនក្រីក្រ។ ផ្អែកលើមូលដ្ឋាននេះ គណៈមេធាវីបានខិតខំស្វែងរកថវិកាមកពីប្រភពផ្សេងៗ ជាពិសេសគណៈមេធាវី បានទទួលជំនួយពីរាជរដ្ឋាភិបាល ដើម្បីឱ្យសកម្មភាពនេះប្រព្រឹត្តទៅបានល្អ។ ទោះជាយ៉ាងនេះក្ដី ថវិកាទាំងនេះគឺមានកំណត់។ ស្ថិតក្នុងស្ថានភាពបែបនេះ ទើបគណៈមេធាវី ចាត់តាំងមេធាវីជួយការពារក្ដីជូនជនក្រីក្រតែក្នុងរឿងក្ដីព្រហ្មទណ្ឌចំពោះ៖

ក.ជនជាប់សង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទជាជនក្រីក្រ ហើយជាប់ចោទពីបទឧក្រិដ្ឋ។

ខ.ជនជាប់សង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទជាអនីតិជន ហើយជាប់ចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។

គ.ជនដែលរងគ្រោះនៅក្នុងបទឧក្រិដ្ឋ និងគ្មានលទ្ធភាពរកមេធាវីការពារខ្លួនដោយខ្លួនឯងបាន។

ចំពោះរឿងក្ដីរដ្ឋប្បវេណី ប្រធានគណៈមេធាវីមានឆន្ទានុសិទ្ធិក្នុងការសម្រេចចាត់តាំងមេធាវីឱ្យការពារក្ដីតាមស្ថានភាពជាក់ស្ដែង និងតាមថវិកាដែលមាន។

មុននឹងសម្រេចទទួលការពាររឿងក្ដី អង្គភាពមានសមត្ថកិច្ចទទួលពាក្យសុំនៃគណៈមេធាវីត្រូវត្រួតពិនិត្យរាល់លក្ខខណ្ឌដូចបានកំណត់នៅក្នុងគោលការណ៍នេះ ដោយរួមបញ្ចូលទាំងទំនាស់ផលប្រយោជន៍ ដូចបានកំណត់ក្នុងក្រមសីលធម៌មេធាវី។

### ២.២ អ្នកដែលមានសិទ្ធិពឹងពាក់

ជនដែលមានចែងនៅក្នុងប្រការ ២.១ ខាងលើ អាចពឹងពាក់រកសេវាមេធាវីរបស់គណៈមេធាវីបាន។ សាមីជនអាចពឹងពាក់ដោយខ្លួនឯង ឬអាចពឹងពាក់តាមរយៈសហព័ទ្ធ កូន ឪពុក-ម្ដាយរបស់គាត់ ឬតាមរយៈតុលាការក៏បាន។

ទោះបីជាសាមីខ្លួនបានបំពេញតាមលក្ខខណ្ឌដូចមានចែងនៅក្នុងគោលការណ៍នេះក៏ដោយ គណៈមេធាវីមានសិទ្ធិមិនផ្ដល់មេធាវីជួយការពារក្ដីបាន អាស្រ័យដោយមូលហេតុថវិកាសម្រាប់ការពារក្ដីជូនជនក្រីក្រនៅមានកំរិត។

## ប្រការ ៣. និយមន័យនៃជនក្រីក្រ

ដើម្បីកំណត់និយមន័យនៃជនក្រីក្រ លក្ខណៈវិនិច្ឆ័យ ២ យ៉ាងនឹងត្រូវយកមកប្រើ៖ (១) គោលការណ៍ទូទៅ និង (២) ភស្តុតាងជាក់លាក់ដែលបញ្ជាក់ភាពក្រីក្រ។

### ៣.១ គោលការណ៍ទូទៅ

ជាទូទៅ ជនក្រីក្រគឺជាជនដែលកំណត់ដោយលក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យលេខ២៩១ អនក្រ ចុះថ្ងៃទី២៧ ធ្នូ ២០១១ ស្ដីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ លក្ខណៈវិនិច្ឆ័យទាំងនោះមាន៖

- ស្ថានភាពផ្ទះរួមមានដំបូល ជញ្ជាំង ផ្ទៃក្រឡា គុណភាពផ្ទះ (ព្រមទាំងបញ្ជាក់ថាជាកម្មសិទ្ធិផ្ទាល់ ឬជួលគេ)
- ទំហំដីលំនៅឋាន និងដីកសិកម្មដែលបានកាន់កាប់ដោយស្របច្បាប់
- ប្រភពចំណូលចម្បងដែលបានមកពីការដាំដុះ ឬនេសាទ ឬសកម្មភាពផ្សេងទៀត
- ការចិញ្ចឹមសត្វ (ដូចជា ការចិញ្ចឹមត្រីសម្រាប់លក់)
- លទ្ធភាពដោះស្រាយស្បៀងអាហារ
- ចំនួនសមាជិកគ្រួសារដែលរកចំណូលមិនបាន ដោយធៀបនឹងចំនួនសមាជិកសរុប
- សម្ភារៈ និងឧបករណ៍ប្រើប្រាស់
- មធ្យោបាយធ្វើដំណើរ
- បញ្ហាថែទាំ ឬវិបត្តិធ្ងន់ធ្ងរដែលបណ្តាលឱ្យគ្រួសារបាត់បង់ចំណូល ខ្វះខាតម្ហូបអាហារ លក់ទ្រព្យសម្បត្តិ ឬជំពាក់បំណុល
- ចំនួនក្មេងដែលមានអាយុពី ៦ឆ្នាំ ដល់ ១១ឆ្នាំ ខកខានរៀននៅសាលា និងមូលហេតុ
- ស្ថានភាពដែលធ្វើឱ្យជីវភាពគ្រួសារធ្លាក់ចុះដូចជា មេគ្រួសារ (ប្តី ឬប្រពន្ធ) ពិការធ្ងន់ធ្ងរ ឬមានជម្ងឺរ៉ាំរ៉ៃ គ្រួសារដែលមានសមាជិកជាស្ត្រីមេម៉ាយមានកូនតូចៗជាច្រើន ឬគ្រួសារគ្មានកំលាំងពលកម្ម
- ស្ថានភាពដែលធ្វើឱ្យជីវភាពគ្រួសារប្រសើរឡើងដូចជា ជំនួយពីសាច់ញាតិ ឬប្រភពផ្សេងទៀត ។

ដើម្បីបញ្ជាក់ពីកម្រិតក្រីក្រ អង្គភាពមានសមត្ថកិច្ចទទួលពាក្យសុំនៃគណៈមេធាវីអាចប្រើ "បញ្ជីសំណួរសម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ" ដែលមានជូនភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ១ នៃគោលការណ៍នេះ ។

នៅក្នុងករណីខ្លះ កាលណាមានការលំបាកក្នុងការកំណត់ពីភាពក្រីក្រ ប្រធានគណៈមេធាវីអាចធ្វើការអារកាត់ថាជនណាម្នាក់ជាជនក្រីក្រ ក្នុងគោលបំណងផ្តល់យុត្តិធម៌សង្គម ។

### ៣.២ ភស្តុតាងជាក់លាក់ដែលបញ្ជាក់ភាពក្រីក្រ

ជនក្រីក្រគឺជាជនដែលត្រូវបានកំណត់ដោយការធ្វើអត្តសញ្ញាណកម្មដោយអាជ្ញាធរមូលដ្ឋាន ដែលតាមរយៈនេះ អាជ្ញាធរមូលដ្ឋានបានចេញប័ណ្ណសមធម៌ ក ១ និង ក ២។ គំរូនៃប័ណ្ណសមធម៌ត្រូវបានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី ២ នៃគោលការណ៍នេះ ។

## ប្រការ ៤. នីតិវិធីនៃការស្នើសុំ

### ៤.១ អង្គភាពមានសមត្ថកិច្ចទទួលពាក្យសុំ

អង្គភាពមានសមត្ថកិច្ចទទួលពាក្យសុំនៃគណៈមេធាវី រួមមាន៖

-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-ការិយាល័យប្រតិភូគណៈមេធាវីប្រចាំសាលាដំបូងរាជធានី ឬ ខេត្ត

-សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ។

ជនគ្រប់រូបដែលមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ២.២ នៃគោលការណ៍នេះអាចដាក់ពាក្យសុំដោយផ្ទាល់ ឬតាមរយៈប្តី ប្រពន្ធ កូន ឪពុក ឬម្តាយ មកគណៈមេធាវី ឬ ដាក់ពាក្យសុំទៅការិយាល័យប្រតិភូគណៈមេធាវីនៅតាមបណ្តារាជធានី ឬ ខេត្តនានា ដែលមានទីតាំងនៅតាមសាលាដំបូងរាជធានី-ខេត្ត ។

អង្គការសង្គមស៊ីវិល តុលាការ ឬក្រសួងយុត្តិធម៌អាចដាក់សំណើសុំជួយការពារក្តីជូនជូនជនក្រីក្រមកគណៈមេធាវី ឬតាមរយៈការិយាល័យប្រតិភូគណៈមេធាវីប្រចាំសាលាជម្រះក្តី នៅតាមបណ្តារាជធានី-ខេត្តនីមួយៗ ។

## ៤.២ ទម្រង់លិខិតស្នើសុំជំនួយផ្នែកច្បាប់

ពាក្យស្នើសុំត្រូវធ្វើតាមទម្រង់របស់គណៈមេធាវី តាមគំរូទី១ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី ៣ នៃគោលការណ៍នេះ ដោយបំពេញលក្ខខណ្ឌដូចមានចែងខាងក្រោម ៖

ក. អ្នកស្នើសុំត្រូវជាជនក្រីក្រដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យ ដូចបានកំណត់នៅក្នុងប្រការ៣ នៃគោលការណ៍នេះ ឬ

ខ. មានលិខិតបញ្ជាក់ពីភាពក្រីក្រចេញដោយអាជ្ញាធរមូលដ្ឋាន ពោលគឺប័ណ្ណសមធម៌ ក១ និង ក២ ដែលមានសំណៅគំរូភ្ជាប់មកជាមួយ ឬ

គ. ជនដែលមានចែងនៅក្នុងប្រការ ២ ចំណុច គ នៃគោលការណ៍នេះ ។

## ៤.៣ ការបែងចែករឿងក្តី

ក្រោយពីទទួលពាក្យស្នើសុំ នាយកដ្ឋានការពារក្តីជូនជនក្រីក្រ ឬប្រតិភូគណៈមេធាវីដែលមានសមត្ថកិច្ចត្រូវបែងចែករឿងក្តីទាំងនោះឱ្យមានតម្លាភាព តាមរបៀបវិលជុំតាមវេន ជូនមេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រ ក្រោមការត្រួតពិនិត្យរបស់អគ្គលេខាធិការ និងការសម្រេចរបស់ប្រធានគណៈមេធាវី ។

ក្នុងករណីមេធាវីដែលដល់វេនមិនអាចមានលទ្ធភាពទទួលការពាររឿងនោះបាន នាយកដ្ឋានការពារក្តីជូនជនក្រីក្រឬ ប្រតិភូគណៈមេធាវីត្រូវបែងចែករឿងក្តីជូនមេធាវី ដែលមានវេនបន្ទាប់ ពីមេធាវីរូបនោះ ។

ការបែងចែករឿងក្តីត្រូវផ្តល់អាទិភាពជូនមេធាវីដែលកំពុងបំពេញកម្មសិក្សា ឱ្យបានក្នុងម្នាក់ៗយ៉ាងតិច ៣ ករណីក្នុង ១ឆ្នាំ ។

ក្នុងករណីពិសេស ប្រធានគណៈមេធាវីមានអំណាចក្នុងការបែងចែករឿងក្តីខុសពីគោលការណ៍បែងចែករឿងក្តីខាងលើបានដោយអនុលោមតាមជំនាញ និងបទពិសោធន៍របស់មេធាវី ឱ្យស្របទៅនឹងប្រភេទរឿងក្តី ឬកូនក្តីនោះ ឬក្នុងកាលៈទេសៈដែលខេត្តណាមួយមិនទាន់មានប្រតិភូគណៈមេធាវីនៅទីនោះ ។

នាយកដ្ឋានការពារក្តីជូនជនក្រីក្រត្រូវរៀបចំបញ្ជីឈ្មោះមេធាវីកម្មសិក្សា និងបញ្ជីឈ្មោះមេធាវីដែលស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រនៅតាមបណ្តារាជធានី ឬខេត្ត ដើម្បីសុំការឯកភាពពីប្រធានគណៈមេធាវី ។

## ៤.៤ ការចាត់តាំង

ជាទូទៅបន្ទាប់ពីបានទទួលលិខិតស្នើសុំជំនួយផ្នែកច្បាប់ពីជនគ្រប់រូប ដែលមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ២.២ នៃគោលការណ៍នេះ ឬពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយអនុលោមតាមលិខិតរបស់ចៅក្រម

សេុបសួរ ចៅក្រមជំនុំជម្រះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ប្រធានសាលាដំបូងរាជធានី-ខេត្ត ប្រធានសាលាឧទ្ធរណ៍ ឬប្រធានតុលាការកំពូល ប្រធានគណៈមេធាវីចាត់តាំងមេធាវីការពារក្តីជូនជនក្រីក្រ ឱ្យជួយការពារសិទ្ធិឱ្យជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ។

ក្នុងករណីបន្ទាន់ ប្រធានគណៈមេធាវីចាត់តាំងមេធាវីការពារក្តីជូនជនក្រីក្រ តាមភាពចាំបាច់ ។ ប្រធានគណៈមេធាវីអាចធ្វើប្រតិភូកម្មអំណាចជាទូទៅ ឬដោយចំពោះរឿងក្តីណាមួយរបស់ខ្លួនជូនប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្តនីមួយៗ ។

## ប្រការ ៥. ការចុះស៊ើបអង្កេត

មេធាវីដែលទទួលការចាត់តាំង ឬទទួលការការពារក្តីជូនជនក្រីក្រដោយស្ម័គ្រចិត្តត្រូវបំពេញកាតព្វកិច្ចការពារក្តីឱ្យបានពេញលេញឱ្យដូចរឿងក្តីដែលកូនក្តីបង់សេវាជូនខ្លួនផងដែរ ។ មេធាវីត្រូវចុះជួបកូនក្តី ពិនិត្យសំណុំរឿង និងចុះស៊ើបអង្កេត តាមទំហំនៃរឿងក្តី ។ ការចុះស៊ើបអង្កេតត្រូវតែមានការអនុញ្ញាត ពីប្រធានគណៈមេធាវី ឬប្រតិភូគណៈមេធាវី ។

រាល់កិច្ចការ និងលទ្ធផលនៃការស៊ើបអង្កេតរបស់មេធាវីត្រូវកត់ត្រាទុក និងដាក់ចូលសំណុំរឿង ។ ក្រមសីលធម៌មេធាវីត្រូវតែគោរព ហើយមេធាវីដែលបំពេញកិច្ចការនេះមិនអាចទារយកថ្លៃសេវាមេធាវី ឬសោហ៊ុយចំណាយពីកូនក្តីបានឡើយ ។

## ប្រការ ៦. ការចំណាយ

រាល់ការចំណាយត្រូវមានបង្កាន់ដៃនៃការចំណាយជាក់ស្តែង ដោយផ្អែកលើគោលការណ៍ចំណាយរបស់គណៈមេធាវី និងម្ចាស់ជំនួយ និងអនុលោមតាមតារាងតម្លៃនៃការចំណាយក្នុងពេលចុះបំពេញបេសកកម្មទៅកាន់រាជធានី-ខេត្តនានា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ៤ នៃគោលការណ៍នេះ ។

រាល់ការចំណាយណាមួយ ដែលលើសពីគោលការណ៍ ឬមិនមានបង្កាន់ដៃចំណាយ ឬមិនបានដាក់ពាក្យស្នើសុំទូទាត់ការចំណាយនោះឱ្យបានទាន់ពេលវេលា គណៈមេធាវីនឹងមិនទទួលខុសត្រូវលើការចំណាយនោះទេ ។ មេធាវីត្រូវចំណាយប្រាក់របស់ខ្លួនជាមុន ទើបដាក់សំណើសុំទូទាត់ជាក្រោយ ។

នាយកដ្ឋានការពារក្តីជូនជនក្រីក្រ ឬប្រតិភូគណៈមេធាវី ត្រូវពិនិត្យលើការស្នើសុំ និងឯកសារចំណាយរបស់មេធាវី ដែលទទួលបានការចាត់តាំងឱ្យការពារក្តីជូនជនក្រីក្រ និងត្រូវចុះមូលវិចារណ៍លើឯកសារទាំងអស់បញ្ជូនមកប្រធានគណៈមេធាវីដើម្បីពិនិត្យ និងសម្រេចចុងក្រោយ ។

ក្រោយពីបានទទួលការសម្រេចឱ្យចំណាយរួចហើយ បេឡាត្រូវប្រគល់ប្រាក់ដែលត្រូវចំណាយនោះជូនមេធាវី ដែលទទួលបានការចាត់តាំងឱ្យការពារក្តីជូនជនក្រីក្រដោយផ្ទាល់ ឬតាមរយៈប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្តឱ្យទាន់ពេលវេលា ។

នៅតាមរាជធានី-ខេត្តនីមួយៗ ប្រតិភូគណៈមេធាវីត្រូវបង្កើតគណនីមួយ សំរាប់ទទួលគំរោងថវិកាសម្រាប់ការចំណាយក្នុងរាជធានីឬខេត្តរបស់ខ្លួន ។

**ប្រការ ៧. ការរៀបចំឯកសារចំណាយ និងការស្នើសុំថវិកា**

មេធាវីដែលទទួលបានការចាត់តាំងឱ្យការពារក្តីជូនជនក្រីក្រត្រូវរៀបចំឯកសារចំណាយ និងស្នើសុំមកប្រធានគណៈមេធាវី តាមរយៈប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ឬតាមរយៈនាយកដ្ឋានការពារក្តីជូនជនក្រីក្រ ក្នុងអំឡុងពេលមិនលើសពី ១ (មួយ) សប្តាហ៍ បន្ទាប់ពីបានចុះបេសកកម្ម។ ការស្នើសុំហួសរយៈពេលនេះ គណៈមេធាវីមិនទទួលខុសត្រូវក្នុងការទូទាត់ជូនឡើយ លើកលែងតែមានមូលហេតុត្រឹមត្រូវដោយមានភ្ជាប់ជាមួយនូវភស្តុតាងគួរជឿទុកចិត្តបាន។

ឯកសារចំណាយអាចជា វិក្កយបត្រដែលចេញដោយផ្ទះសំណាក់ ឬសណ្ឋាគារសម្រាប់ការស្នាក់នៅផ្ទាល់ វិក្កយបត្រថ្លៃថតចម្លងសំណុំរឿង (គំរូទី១ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃគោលការណ៍នេះ) វិក្កយបត្រថ្លៃធ្វើដំណើរផ្លូវឆ្ងាយ (គំរូទី២ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃគោលការណ៍នេះ) វិក្កយបត្រថ្លៃធ្វើដំណើរទៅជួបកូនក្តីក្នុងពន្ធនាគារ (គំរូទី៣ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃគោលការណ៍នេះ) និងវិក្កយបត្រថ្លៃធ្វើដំណើរក្នុងក្រុង (គំរូទី៤ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃគោលការណ៍នេះ)។ ចំពោះថ្លៃហូបចុកមិនចាំបាច់មានវិក្កយបត្រទេ។

**ប្រការ ៨. ការធ្វើរបាយការណ៍**

មេធាវីម្នាក់ៗដែលទទួលបានការចាត់តាំង ឬទទួលការការពារជនក្រីក្រដោយស្ម័គ្រចិត្តត្រូវធ្វើរបាយការណ៍រឿងក្តីជូននាយកដ្ឋានការពារក្តីជូនជនក្រីក្រនៃគណៈមេធាវី ដោយផ្ទាល់ ឬតាមរយៈប្រតិភូគណៈមេធាវីជារៀងរាល់ខែតាមគំរូរបាយការណ៍របស់គណៈមេធាវីដែលភ្ជាប់ជាឧបសម្ព័ន្ធទី ៦ នៃការណ៍នេះ។

ប្រតិភូគណៈមេធាវីនៃរាជធានី-ខេត្តនីមួយៗត្រូវធ្វើរបាយការណ៍សរុបនូវរឿងក្តីទាំងអស់ នៅក្នុងរាជធានីឬខេត្តរបស់ខ្លួនជូនមកគណៈមេធាវី។ ក្រោយទទួលបានរបាយកាណ៍ពីមេធាវីម្នាក់ៗ ឬប្រតិភូគណៈមេធាវីរួចមក នាយកដ្ឋានការពារក្តីជនក្រីក្រត្រូវបញ្ចូលទិន្នន័យក្នុងប្រព័ន្ធទិន្នន័យរួមរបស់គណៈមេធាវី។

នាយកដ្ឋានការពារក្តីជូនជនក្រីក្រត្រូវធ្វើរបាយការណ៍សរុបប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនប្រធានគណៈមេធាវី ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានភ្ជាប់នូវឯកសារពាក់ព័ន្ធប្រសិនបើចាំបាច់ (គំរូរបាយការណ៍នេះភ្ជាប់ជាឧបសម្ព័ន្ធទី ៧ នៃគោលការណ៍នេះ)។

**ប្រការ ៩. ការគ្រប់គ្រងរឿងក្តី**

រាល់សំណុំរឿងក្តីការពារជនក្រីក្រ ដែលបានបញ្ចប់ទាំងអស់របស់មេធាវី នៅតាមរាជធានី-ខេត្តត្រូវរក្សាទុកនៅការិយាល័យប្រតិភូរបស់គណៈមេធាវីនៅតាមរាជធានី-ខេត្តរបស់ខ្លួន។ ចំពោះមេធាវីបំរើការនៅនាយកដ្ឋានការពារក្តីជូនជនក្រីក្រត្រូវរក្សាទុកសំណុំរឿងនៅនាយកដ្ឋានការពារក្តីជូនជនក្រីក្រ។

មេធាវីដែលទទួលបានការចាត់តាំងឱ្យការពារក្តីត្រូវគ្រប់គ្រងរាល់ឯកសារនៃសំណុំរឿងរបស់ខ្លួន និងធានាការសំងាត់រវាងកូនក្តី និងមេធាវី។

ប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្តត្រូវគ្រប់គ្រងរឿងក្តីក្នុងដែនរាជធានី-ខេត្តរបស់ខ្លួន ហើយត្រូវផ្តល់ឯកសារ និងព័ត៌មានជូនប្រធានគណៈមេធាវី និងនាយកដ្ឋានការពារក្តីជូនជនក្រីក្រតាមតម្រូវការ។

នាយកដ្ឋានការពារក្ដីជូនជនក្រីក្រត្រូវគ្រប់គ្រងឯកសារ និងទិន្នន័យនៃរឿងក្ដី ដែលគណៈមេធាវីបានទទួលទូទាំងប្រទេស ហើយត្រូវផ្ដល់ឯកសារ និងព័ត៌មានជូនប្រធានគណៈមេធាវីតាមតម្រូវការ ។

អ្នកគ្រប់គ្រងរឿងក្ដី ឬលេខាធិការត្រូវរក្សាការសម្ងាត់នៃរឿងក្ដីតាមវិជ្ជាជីវៈ ។ គ្រប់រឿងក្ដីការពារក្ដីជូនជនក្រីក្រទាំងអស់របស់គណៈមេធាវីត្រូវចុះបញ្ជីនៅក្នុងសៀវភៅតាមដានរឿងក្ដី និងបញ្ចូលព័ត៌មាននៃរឿងក្ដីទាំងនោះនៅក្នុងប្រព័ន្ធទិន្នន័យរួមរបស់គណៈមេធាវី ។

## ប្រការ ១០. ការទទួលខុសត្រូវ និងត្រួតពិនិត្យ

មេធាវីដែលទទួលបានការចាត់តាំងឱ្យការពារក្ដីជូនជនក្រីក្រត្រូវតែខិតខំប្រឹងប្រែងការពារកូនក្ដី ឱ្យអស់ពីសមត្ថភាព និងឱ្យទាន់ពេលវេលា ដោយគោរពយ៉ាងខ្ជាប់ខ្ជួននូវវិធានវិជ្ជាជីវៈដូចមានកំណត់ក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី និងក្រមសីលធម៌មេធាវី ព្រមទាំងសេចក្ដីសម្រេចទាំងឡាយរបស់គណៈមេធាវី ។

ប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្តត្រូវត្រួតពិនិត្យផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេសក្នុងកំរិតមិនប៉ះពាល់ដល់ការសម្ងាត់វិជ្ជាជីវៈ និងភាពជាម្ចាស់លើការប្រើប្រាស់មធ្យោបាយការពារក្ដីរបស់មេធាវី ដែលទទួលបានការចាត់តាំងឱ្យការពារក្ដីជូនជនក្រីក្រក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

នាយកដ្ឋានការពារក្ដីជូនជនក្រីក្រត្រូវត្រួតពិនិត្យផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេសក្នុងកំរិតមិនប៉ះពាល់ដល់ការសម្ងាត់វិជ្ជាជីវៈ និងភាពជាម្ចាស់លើការប្រើប្រាស់មធ្យោបាយការពារក្ដីរបស់មេធាវីដែលទទួលបានការចាត់តាំងឱ្យការពារក្ដីជូនជនក្រីក្រទាំងអស់ ។

## ប្រការ ១១. កាតព្វកិច្ចមេធាវីទូទៅ

មេធាវីម្នាក់ៗមានកាតព្វកិច្ចការពារក្ដីជូនជនក្រីក្រចំនួន ៣ ករណីយ៉ាងតិចក្នុង ១ឆ្នាំ ។ ក្នុងករណីមេធាវីរូបនោះមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីបំពេញកិច្ចការនេះ មេធាវីរូបនោះអាចបង់ប្រាក់ឱ្យមេធាវីផ្សេងទៀតឱ្យការពារជំនួសតាមការព្រមព្រៀង ។

## ប្រការ ១២. ការដាក់វិន័យ

មេធាវី ឬ បុគ្គលិកណាម្នាក់ ដែលកំពុងបំរើការងារជូនគណៈមេធាវី នៅក្រោមគោលការណ៍នេះ ហើយបានប្រព្រឹត្តខុសវិធានដែលមានចែងក្នុងគោលកាណ៍នេះនឹងរងទណ្ឌកម្មវិន័យផ្នែករដ្ឋបាល ។ ក្នុងករណីធ្ងន់ធ្ងរ បុគ្គលរូបនោះនឹងត្រូវប្រឈមមុននឹងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ ។

## ប្រការ ១៣. ការលើកទឹកចិត្ត

មេធាវីដែលបានបំរើការងារជូនគណៈមេធាវីក្នុងវិស័យការពារក្ដីជូនជនក្រីក្រនឹងទទួលបានរង្វាន់លើកទឹកចិត្តចំពោះកិច្ចការរបស់ខ្លួនតាមទំហំការជោគជ័យជារៀងរាល់ឆ្នាំ ។

**ប្រការ ១៤. ប្រភពមូលនិធិ**

គណៈមេធាវីអាចទទួលមូលនិធិពីរាជរដ្ឋាភិបាល ពីមេធាវី ឬពីសប្បុរសជននានាសំរាប់បំរើការងារផ្តល់សេវាកម្មការពារក្តីជូនជនក្រីក្រ ដោយមិនយកកម្រៃ ។

គណៈមេធាវីត្រូវចាត់ចែងមូលនិធិទាំងនេះឱ្យមានតម្លាភាពប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ១៥. ការចូលជាធរមាន**

គោលការណ៍នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ដោយប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ១៦. ការអនុវត្តន៍**

អគ្គលេខាធិការ ប្រធាននាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានការពារក្តីជូនជនក្រីក្រ ប្រតិភូគណៈមេធាវី និងមេធាវីត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៨ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ [illegible] ខែមករា ឆ្នាំ២០១៨

**មេធាវី សួន_វិសាល**